# រឿងពិតកម្មករកាត់ដេរ

លំនាំបទៈ  យន្តហោះបោះពួយ

១ នេះជារឿងពិតមិនប្រឌិតទេ | ច្រៀងផ្ដាំស្រីខ្មែរទូទាំងលោកីយ៍
ជីវិតកម្មករលំបាកស្ទើរក្ស័យ | រស់គ្មានសេរីត្រូវគេរើសអើង ។

២ ខំប្រឹងធ្វើការទោះក្ដៅត្រជាក់ | គ្រុនរងារញាក់ក៏នៅស៊ូទ្រាំ
ខ្លាចគេកាត់លុយនិងបណ្ដេញចេញ | ដួងចិត្តទោម្នេញពោរពេញដោយទុក្ខ។

បន្ទរ រាល់ថ្ងៃធ្វើការក្នុងចិត្តភិតភ័យ | ឱ!កម្មករស្រីត្រូវគិតយ៉ាងណា
ឆ្នាំពីរពាន់ប្រាំបញ្ចប់កូដតា | តើឱ្យគ្រួសារយើងរស់ម្ដេចទៅ?

៣ វីរភាពយើងគេមិនឱ្យតំលៃ | តាមពិតមានន័យថ្លៃគ្មានអ្វីប្រៀប
សព្វថ្ងៃកម្មករជួយជាតិយ៉ាងខ្លាំង | យើងជាកំលាំងជួយសេដ្ឋកិច្ចខ្មែរ ។


កម្មវិធីកម្មកររោងចក្រកាត់ដេរ ©២០០៥